**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៧៤៧ **ក.ប**/ស.ជ.ណ.រ.ប.ប

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## មណ្ឌលប្រឡងជ្រើសរើស
## ក្របខ័ណ្ឌថ្មីឆ្នាំ២០១៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ និងមន្ត្រីរាជការទាំងពីរភេទឲ្យបានជ្រាបថា មណ្ឌលប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីឆ្នាំ២០១៧ តាមខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ ០៨៦/១៧ ក.ប/ស.ជ.ណ.រ.ប.ប ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកាលបរិច្ឆេទប្រឡងនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ គឺនៅមណ្ឌល "វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ" ស្ថិតនៅតាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី ជាប់នឹងរបងវត្តទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

<u>សូមបញ្ជាក់ជូនបេក្ខជន បេក្ខនារីផងដែរថា ៖</u>

- បញ្ជីឈ្មោះបេក្ខជន បេក្ខនារីនឹងបិទផ្សាយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ដែលមានបិទនៅមណ្ឌលប្រឡង (វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ) និងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វេលាម៉ោង ១០:០០ព្រឹក
- បេក្ខជន បេក្ខនារី ដែលមានឈ្មោះក្នុងបញ្ជីត្រូវមកដល់បន្ទប់ប្រឡងនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ យ៉ាងយូរត្រឹមម៉ោង៦:០០ព្រឹក ។ ក្នុងករណីបេក្ខជន បេក្ខនារី ដែលមកដល់មណ្ឌលប្រឡងយឺត១៥នាទីក្រោយពីចែកវិញ្ញាសាប្រឡង មិនត្រូវបានអនុញ្ញាតឲ្យចូលប្រឡងឡើយ
- ករណីបេក្ខជន បេក្ខនារីដែលខកខានមិនបានគោរពទៅតាមការកំណត់នេះទេ គណៈកម្មការប្រឡងក្របខ័ណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទទួលខុសត្រូវលើការបាត់បង់បេក្ខភាពប្រឡងឡើយ ។

អាស្រ័យហេតុនេះ សូមបេក្ខជន បេក្ខនារីទាំងអស់អនុវត្ត និងជ្រាបជាព័ត៌មាន ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩